# ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

## មាតិកា

### ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៧-១២-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១២០១/៤៥៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់លោក **អ៊ូច យ៉ាំងហុង** ( AU YEUNG HUNG )ជនជាតិវៀតណាមសញ្ជាតិអាមេរិក ៣២៤៨

១៧-១២-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១២០១/៤៥៨ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **យឹម លាង** អត្តលេខ ០០៥១៨២ មេបញ្ជាការអង្គរក្សសម្តេចប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រ កម្ពុជា ៣២៤៩

១៧-១២-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១២០១/៤៥៩ ស្តីពីការតែងតាំងឯកឧត្តម **សួង ម៉េងសា** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ៣២៥០

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៩-១២-២០០១ - អនុក្រឹត្យលេខ ១២៧ អនក្រ. បក ស្តីពីការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាគ្រឹះស្ថានសាធារណរដ្ឋបាល ៣២៥១

២១-១២-២០០១ - អនុក្រឹត្យលេខ ១២៨ អនក្រ. បក ស្តីពីការផ្ទេរឥណទានថវិកា ៣២៦៦

១៤-១២-២០០១ - អនុក្រឹត្យលេខ ៥១៨ អនក្រ. តត ស្តីពីការតែងតាំងតម្លើងឋានន្តរសក្តិនាយទាហាន ៣២៦៨

១៤-១២-២០០១ - អនុក្រឹត្យលេខ ៥១៩ អនក្រ. តត ស្តីពីការតែងតាំងមុខតំណែងនាយទាហាន ៣២៦៩

១៧-១២-២០០១ - អនុក្រឹត្យលេខ ៥២០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៧០

១៧-១២-២០០១ - អនុក្រឹត្យលេខ៥២១ អនក្រ. តត ស្តីពីការជូនមេដាយសហមេត្រីនិងមេដាយ ការងារ ៣២៧១

១៨-១២-២០០១ - អនុក្រឹត្យលេខ ៥២២ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៧៣

១៩-១២-២០០១ - អនុក្រឹត្យលេខ ៥២៣ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៧៥

១៩-១២-២០០១ - អនុក្រឹត្យលេខ ៥២៤ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៧៦

២០-១២-២០០១ - អនុក្រឹត្យលេខ ៥២៥ អនក្រ. តត ស្តីពីការជូនមេដាយការងារ ៣២៧៨

២១-១២-២០០១ - អនុក្រឹត្យលេខ ៥២៦ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣០០

២១-១២-២០០១ - អនុក្រឹត្យលេខ ៥២៧ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣០១

២១-១២-២០០១ - អនុក្រឹត្យលេខ ៥២៨ អនក្រ. តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៣០២

២១-១២-២០០១ - អនុក្រឹត្យលេខ ៥២៩ អនក្រ. តត ស្តីពីការជូនមេដាយការងារ ៣៣០៣
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣០ អនក្រ. តត ស្តីពីការជូនមេដាយការងារ ៣៣០៥
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣១ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣០៦
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣២ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣០៧
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣៣ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣០៨
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣៤ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣១០
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣៥ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៣១១
២១-១២-២០០១ - អនុក្រឹត្យលេខ ៥៣៦ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៣១២

## ២.សេចក្តីសំរេច

២០-១២-២០០១ - សេចក្តីសំរេចលេខ ៧៥ សសរ ស្តីពីការប្តូរប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយ សំរបសំរួលជាមួយប្រជាពលរដ្ឋដែលកាន់កាប់ដីធ្លីបុរីសណ្ឋាគារ អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា ៣៣១៣

## ៣.សារាចរណែនាំ

១៨-១២-២០០១ - សារាចរណែនាំលេខ ១៤ សរណន ស្តីពីការពង្រឹង និង ជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ ក្នុងសភាពការថ្មី ៣៣១៥

## ៤. លិខិតបញ្ជា

១៩-១២-២០០១ - លិខិតបញ្ជាលេខ ០២ បប ស្តីពីវិធានការបង្កើនប្រសិទ្ធភាពទប់ស្កាត់និងបង្ក្រាបអំពើរត់ពន្ធ ៣៣១៩

# III- ការងារបណ្តាក្រសួង

## ១. ទីស្តីការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-១២-២០០១ - ប្រកាសលេខ ៩៣៣ សហវ.ឧហ ស្តីពីការប្រើប្រាស់ស្លាកយីហោរបស់ ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ៣៣២៣
១៧-១២-២០០១ - ប្រកាសលេខ ៩៣៤ សហវ.ឧហ ស្តីពីការកំណត់ទូទៅចំពោះប្រតិបត្តិករធានារ៉ាប់រង ៣៣២៦
១៧-១២-២០០១ - ប្រកាសលេខ ៩៣៦ សហវ.ប្រក ស្តីពីការកែសំរួលអត្រាពន្ធ និងអាករ លើទំនិញមួយចំនួន ( ស្រាបៀរ) ៣៣៣០
២០-១២-២០០១ - សេចក្តីជូនដំណឹងលេខ ០២៩ សហវ.ឧហ ស្តីពីការបើកទូលាយទីផ្សារធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា ៣៣៣៣

## ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២០-១២-២០០១ -ប្រកាសលេខ ១៤៥ ប្រក.បបប /២០០១ ស្តីពីការផ្ទេរក្របខ័ណ្ឌនិងឥណទាន

ប្រវត្តិរូបរបស់ ក្រឡាបញ្ជី បំរើការនៅតុលាការក្រុងភ្នំពេញចំនួន ៣០រូប ៣៣៣៤

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២០-១២-២០០១ - សេចក្តីសំរេចលេខ ៣១៦ កធស.សរ ស្តីពីការអនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីះឈ្មោះ" រដូវចំរូត" មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិចំការចេក ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ ៣៣៣៦

# ព្រះរាជក្រឹត្យ

យើង

នស / រកត / ១២០១/៤៥៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក អ៊ូ យ៉ាងហុង (AU YEUNG HUNG) ជនជាតិវៀតណាម សញ្ជាតិអាមេរិក កើតថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៦៤ នៅ Saigon ប្រទេសវៀតណាម ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០១
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

លេខ: ៣០៥ ច.ល

៣រស.០១.១៤.០០៥២

ដើម្បីប្រគល់ចែក
រាជធានីភ្នំពេញ, ថ្ងៃទី៤០ ខែ ធ្នូ ឆ្នាំ ២០០១
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សុខ អាន**

# ព្រះរាជក្រឹត្យ

នស / រកត / ១២០១/៤៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **យឹម សាង** អត្តលេខ ០០៥១៨២ នាយទាហាន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ មេបញ្ជាការអង្គរក្សសម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា** លេខ : ៣០៣ ច.ល

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

៣រ.ល.០១.១៧.០០៥៣

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

**សុខ ឆាន**

# ព្រះរាជក្រឹត្យ

## យើង

នស / រកត / ១២០១ / ៤៥៩

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោង តាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម សួង ម៉េងគា ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារ វិនិយោគ អភិវឌ្ឍន៍ និងទេសចរណ៍ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភានិងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

លេខ : ៣០៤ច.ល ហត្ថលេខា

ដើម្បីចម្លងចែក ជា ស៊ីម

៣៦៥-០១-១៧-០០៥៤

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធិ តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :១២៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល

## ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/ ០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ១៩៩៧ស្តីពីលក្ខន្តិកៈ គតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលសរសេរកាត់ថា " **ស.វ.ស.** " ត្រូវបានសំរេចអោយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង ស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២ .-**

**ស.វ.ស.** ជានីតិបុគ្គល និង មានស្វ័យភាព ហិរញ្ញវត្ថុ ។ **ស.វ.ស.** មានអាសយដ្ឋានលេខ ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ការផ្លាស់ប្តូរ អាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ស.វ.ស.** ។

**មាត្រា ៣ .-**

**ស.វ.ស.** មានភារកិច្ចជាអាទិដូចតទៅ :

- បណ្តុះបណ្តាលអ្នកបច្ចេកទេសវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វទនសាស្ត្រ និងថែទាំវេជ្ជសាស្ត្រថ្នាក់ឧត្តមគ្រប់កម្រិត និងធ្វើ វិក្រឹតការ អ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការទូទាំងព្រះរាជាណាចក្រកម្ពុជាតាមប្រព័ន្ធសាកលវិទ្យាល័យតាមរយៈការបង្រៀន ការរៀន និង ការបណ្តុះបណ្តាលមុខរបរវិជ្ជាជីវៈវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វទនសាស្ត្រ វិទ្យាសាស្ត្រថែទាំ ព្រមទាំងបណ្តុះបណ្តាលបន្ត ដែលផ្តល់ជំនាញប្រកបដោយ គុណភាព វិញ្ញាបនបត្រ និងសញ្ញាប័ត្រ ព្រមទាំងរៀបចំ និង បើកសិក្ខាសាលា សន្និសីទផ្សេងៗ តាមសំណូមពរសង្គម
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យសម្រាប់ មហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាលទាំង៣ និងសម្រាប់សាលាបច្ចេកទេស ថែទាំវេជ្ជសាស្ត្រ
- រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល
- **ស.វ.ស.** ផ្តល់និងរួមផ្តល់ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលដទៃទៀតនូវសញ្ញាប័ត្រកម្រិតជាតិ
- រៀបចំ ស្រាវជ្រាវវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្ត-វទនសាស្ត្រ និងវិទ្យាសាស្ត្រថែទាំ
- សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀនចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាខ្មែរ និង ភាសាបរទេសឱ្យបានសមស្របសម្រាប់ប្រើប្រាស់ និងសម្រាប់ផ្សព្វផ្សាយទូទៅ

- រៀបចំនិងដំណើរការការងារប្រឡងជ្រើសរើស និស្សិត សិស្សឱ្យចូលរៀន ប្រឡងចេញ វាយតម្លៃការសិក្សាដោយខ្លួនឯងឱ្យបានត្រឹមត្រូវតាមគោលការណ៍ និង ប្រកបដោយតម្លាភាព

- កសាងផែនការមូលដ្ឋានសម្ភារៈសម្រាប់ **ស.ទ.ស.**

- ដើរតួជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការកសាងធនធានមនុស្ស លើវិស័យសុខាភិបាល

- គ្រប់គ្រងមន្ត្រីរាជការ និយោជិតកម្មករ និស្សិត សិស្ស សាស្ត្រាចារ្យ និង ទ្រព្យសម្បត្តិរបស់ **ស.ទ.ស.**

- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនិងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្របច្ចេកទេស ។

## ជំពូកទី២

## រដ្ឋបាល និង ការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤ .-**

**ស.ទ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែង ការងារក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និង បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា ៥ .-**

៥.១ -ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧ រូប ដែលមានសមាសភាពដូចតទៅ :

- តំណាង ក្រសួងសុខាភិបាល ប្រធាន
- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងអប់រំ យុវជននិងកីឡា សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាសមាជិកស្វ័យប្រវត្តិ
- ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល ០១ រូប សមាជិក
- តំណាងបុគ្គលិក នៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ជាសមាជិកស្វ័យប្រវត្តិ

៥.២- តំណាងបុគ្គលិក នៃ សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោម បុគ្គលិក **ស.វ.ស.** ។

៥.៣ - ប្រធាន និងសមាជិកនៃក្រុមប្រឹក្សាដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់ អាណត្តិ ៣ (បី) ឆ្នាំ រៀបចំដោយក្រសួងសុខាភិបាល តាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់ បានគ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬ ស្ថាប័នដែលខ្លួនតំណាងឱ្យ ។

**មាត្រា ៦ ._**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើស ក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច៥ (ប្រាំ) ឆ្នាំ ឬ ជាឥស្សរជនដែលមានអាយុមិនលើស ពី ៦៥ ឆ្នាំ និងមានបទពិសោធន៍គ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រសុខាភិបាល អប់រំ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មកម្រិតធ្ងន់ពីតុលាការឡើយ ។

**មាត្រា ៧ ._**

៧.១.- ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទី កោះប្រជុំ និងកំណត់របៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

៧.២.- ក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍ លើវិស័យបណ្តុះ បណ្តាលវិទ្យាសាស្ត្រសុខាភិបាល និងតំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនេះ មានសិទ្ធិ ផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោត អនុម័តឡើយ ។

**មាត្រា ៨ ._**

ក្រុមប្រឹក្សាភិបាលមានបេសកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យ លើដំណើការរបស់សាកលវិទ្យាល័យ ។ ក្នុងក្របខ័ណ្ឌ នៃបេសកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ :

- ពិនិត្យ និងសម្រេចលើគំរោងផែនការអភិវឌ្ឍ នៃ **ស.វ.ស.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយជាប្រចាំព្រមទាំងទុន ក្នុងថវិកាប្រចាំឆ្នាំរបស់ **ស.វ.ស.**
- ពិនិត្យ និងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅដល់អង្គភាពក្រោមឱវាទ
- កំណត់នូវរបបជ្រើសរើស ការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការ ដល់បុគ្គលិក **ស.វ.ស.** ដោយមិនប៉ះពាល់ដល់ បទប្បញ្ញត្តិច្បាប់ ឬ បទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះភ្នាក់ងារមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ស.វ.ស.**
- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្ម

- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ស.ម.ស.**
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ស.ម.ស.** ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

**មាត្រា ៩ .-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់សាកលវិទ្យាធិការ ត្រូវកំណត់ដោយរដ្ឋមន្ត្រី ក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាក្រុមប្រឹក្សាភិបាល ។

**មាត្រា ១០ .-**

១០.១.- ក្រុមប្រឹក្សាភិបាល នៃ **ស.ម.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ ( ពីរភាគបី ) ឡើងទៅ ឬ តាមការស្នើសុំពីសាកលវិទ្យាធិការ នៃ **ស.ម.ស.** ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ដែលមានវ័យច្រើនជាងគេ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១ (មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវ ផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច **១០(ដប់)** ថ្ងៃ មុនថ្ងៃប្រជុំ ។

១០.២.- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមានចំនួនលើសពី ៥០(ហាសិប) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មាន សិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ **១៥ (ដប់ប្រាំ )** ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តំរូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវ ពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាន ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព។

១០.៣.-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដកល់ទុក នៅទីស្នាក់ការរបស់ **ស.ម.ស.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និង លេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញ នូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និង ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ពន្ធ័យ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

១០.៤.-**ស.ម.ស.** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ :

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥.- ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

## ផ្នែកទី ២

## អង្គការប្រតិបត្តិរបស់សាកលវិទ្យាល័យ

**មាត្រា ១១ .-**

**ស.វ.ស.** ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ សាកលវិទ្យាធិការនេះមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា ១២ .-**

១២.១ - សាកលវិទ្យាធិការនៃ **ស.វ.ស.** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រងនិងអនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

សាកលវិទ្យាធិការមានភារកិច្ច :

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការ នូវ នយោបាយដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ស.វ.ស.** ហើយដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យសម្រេច
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និង រាល់សកម្មភាព ផ្សេងៗទៀត ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ស.វ.ស.** ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់ **ស.វ.ស.**

ក្រុមប្រឹក្សាភិបាល ស្ដីពីការបែងចែកសិទ្ធអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិ ដទៃទៀតស្ដីពីបញ្ហានេះ

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យ តាមបទបញ្ជាផ្ទៃក្នុងរបស់**ស.វ.ស.** និង តាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២- សាកលវិទ្យាធិការ នៃ **ស.វ.ស.** ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយ តតិយជន ។

១២.៣- សាកលវិទ្យាធិការ នៃ **ស.វ.ស.** ត្រូវស្នើទៅក្រុមប្រឹក្សាភិបាល សុំតែងតាំងសាកលវិទ្យាធិការរងមួយរូប ឬ ពីររូប មានឋានៈស្មើប្រធាន នាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

## ផ្នែកទី៣

## បុគ្គលិករបស់ "ស.វ.ស."

**មាត្រា ១៣ .-**

១៣.១- បុគ្គលិកអចិន្ត្រៃយ៍របស់ **ស.វ.ស.** រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាល ឬ ជ្រើសរើសតាមសំណើរបស់សាកលវិទ្យាធិការ នៃ **ស.វ.ស.** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និង ប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៣.២- សាកលវិទ្យាល័យ អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការនិងបុគ្គលិកអណ្ដែត ។ ភ្នាក់ងារទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និង តាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ ស្ដីពីការងារ ។

១៣.៣- បុគ្គលិក **ស.វ.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្ដីពីបុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃលើកទឹកចិត្ត ចំពោះបុគ្គលិកព្រមទាំងបែបបទ នៃការទូទាត់ផងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤

## ទ្រព្យសម្បត្តិរបស់ " ស.វ.ស. "

**មាត្រា ១៤ .-**

១៤.១- **ស.វ.ស.** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

- ដីជាទីតាំងនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាលមានសមាសភាគផ្ទៃក្នុង ៤ ដែលមានឈ្មោះដូចតទៅ

- មហាវិទ្យាល័យវេជ្ជសាស្ត្រ
- មហាវិទ្យាល័យឱសថសាស្ត្រ
- មហាវិទ្យាល័យទន្ត-វេទនសាស្ត្រ
- សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

មានផ្ទៃដី ១៦៧៤៥ម² ស្ថិតនៅសង្កាត់ ស្រះចក ខ័ណ្ឌ ដូនពេញ និង មានផ្ទៃដី ១១៦៦៧ ម²៨០ ស្ថិតនៅ សង្កាត់ទំនប់ទឹក ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។

១៤.២- ក្រៅពីអចលនទ្រព្យខាងលើ **ស.វ.ស.** ត្រូវបានទទួលនូវចលនទ្រព្យ និងអចលនទ្រព្យផ្សេងៗដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣- អចលនទ្រព្យ និង ចលនទ្រព្យទាំងអស់ របស់ **ស.វ.ស.** មានចែងលម្អិតក្នុងបញ្ជីសារពើភណ្ឌដូចមាន ឧបសម្ព័ន្ធខាងក្រោយ ។

១៤.៤- **ស.វ.ស.** អាចទិញ លក់ចលនទ្រព្យ និង ទិញអចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន ។

## ផ្នែកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ "ស.វ.ស."

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ **ស.វ.ស.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦ .-**

១៦.១- សាកលវិទ្យាធិការនៃ **ស.វ.ស.** ជាអាណាប័កដើមខ្សែរបស់សាកលវិទ្យាល័យ ហើយត្រូវមានភារកិច្ច :

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២-អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវវជ្ជទេយ្យចំណូល ឬ បុរេប្រទានបាន ដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៧ .-**

១៧.១- ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ **ស.ទ.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះត្រូវតែងតាំង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ភ្នាក់ងារគណនេយ្យនេះត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសម្លេងឆ្នោតឡើយ។

១៧.២ - ភ្នាក់ងារគណនេយ្យមានភារកិច្ច :

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់សកលវិទ្យាល័យ
- រក្សាទុកនូវលិខិតយុត្តិការ និង កានកាប់បញ្ជីគណនេយ្យ ។

១៧.៣- ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុករិរបស់ខ្លួន។

**មាត្រា ១៨ .-**

១៨.១- ប្រភពធនធានរបស់ **ស.ទ.ស.** រួមមាន :

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ **ស.ទ.ស.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និង អច្ច័យទានដែល **ស.ទ.ស.** បានទទួល
- ប្រាក់ខ្ចីបុលដោយសាកលវិទ្យាល័យផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ស.ទ.ស.**
- ផលការងារ និងកំរៃនៃការផ្តល់សេវាផ្សេងៗដោយ **ស.ទ.ស.**
- កម្រៃនៃទ្រព្យសម្បត្តិរបស់ **ស.ទ.ស.** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ស.ទ.ស.** ។

១៨.២-ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ស.ទ.ស.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលរបស់ **ស.ទ.ស.** ត្រូវចែងអំពីបែបបទនៃការរៀបចំការចាត់ចែងនិងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទំរង់បែបបទ នៃការរៀបចំការចាត់ចែងនិងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

១៨.៣-ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ស.ទ.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេច

យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ ។

**មាត្រា ១៩ ..**

១៩. ១- ការងារគណនេយ្យរបស់ **ស.ទ.ស.** រួមមាន :

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រត្តិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និង គណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់សាកលវិទ្យាល័យត្រូវ :

១- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ទ.ស.**ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណនេយ្យនេះត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១៩.២- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យនិងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០ ..**

មូលនិធិរបស់ **ស.ទ.ស.**គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិបញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៦

## របបសារពើពន្ធនៃ " ស.ទ.ស."

**មាត្រា ២១ ..**

លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយច្បាប់ **ស.ទ.ស.** ត្រូវស្ថិតនៅក្រោមនីតិរួមចំពោះរបបសារពើពន្ធដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

## ផ្នែកទី ៧

## លទ្ធកម្មរបស់ " ស.ទ.ស."

**មាត្រា ២២ .-**

ការសម្រេច ការអនុវត្ត និង ការត្រួតពិនិត្យ លើលទ្ធកម្មរបស់ **ស.ទ.ស.** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦០ អនក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងបទបញ្ញាដទៃទៀតពាក់ព័ន្ធ នឹងបញ្ហានេះ ។

## ជំពូកទី ៣

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣ .-**

២៣.១- ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមាន ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២- លិខិតយល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង ហើយត្រូវផ្ញើជូនទៅសាកលវិទ្យាធិការនៃ **ស.ទ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ សាកលវិទ្យាធិការនៃ **ស.ទ.ស.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាល មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះកម្មវិធីអភិវឌ្ឍ ឬ គម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាល ធ្វើការជំទាស់លើកម្មវិធី អភិវឌ្ឍ ឬគម្រោង

ថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍនៃ **ស.ទ.ស.** និង ថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមសំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤ ._**

២៤.១- រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារ ដែលបានត្រូវបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា២៣ ខាងលើមាន : កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ ។

២៤.២- សាកលវិទ្យាធិការនៃ **ស.ទ.ស.** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាល សម្រេចពុំយកជាបានការ នូវការជំទាស់ទាំងនេះ សេចក្តីសម្រេចក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ២៥ ._**

២៥.១ - រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការនៃ **ស.ទ.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ :

- ផ្ទុយនឹងគោលដៅរបស់សាកលវិទ្យាល័យ
- ផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ធ្វើផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២-ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួនឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោលឬការផ្អាកទុកនូវ សេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាកលវិទ្យាធិការ នៃ **ស.ទ.ស.** ហើយសកលវិទ្យាធិការត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់សាកលវិទ្យាល័យ ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទ ដែលមានចែងក្នុងច្បាប់ និង បទប្បញ្ញត្តិដែលមានជាធរមាន ។

# ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧ .-**

២៧.១ - ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.វ.ស.** ត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយសាកលវិទ្យាធិការនៃ **ស.វ.ស.**ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២ - លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អ្នកតំណាង ត្រូវផ្ញើទៅសាកលវិទ្យាធិការនៃ **ស.វ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ សាកលវិទ្យាធិការនៃ **ស.វ.ស.** ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល ឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

មាត្រា ២៨ .-

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ **ស.ទ.ស.** ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន :

- សេចក្តីសម្រេចស្តីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និង កិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

មាត្រា ២៩ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ **ស.ទ.ស.** ។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុននិងជាក្រោយលើ **ស.ទ.ស.**ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

មាត្រា ៣០ .-

៣០.១- ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ នៃ **ស.ទ.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៣០.២- ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់ភ្នាក់ងារគណនេយ្យកណ្តាលនៃរតនាគារជាតិ និង ក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។

៣០.៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬ ការត្រួតពិនិត្យលើសាកលវិទ្យាល័យនៅពេលដែលយល់ថា ចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និង បទប្បញ្ញត្តិដែលមានជាធរមាន ។

# ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកា ចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២១៣ លានរៀល ( ពីររយដប់បីលានរៀល ) ពីជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ១៤៥ លានរៀល ( មួយរយសែសិបប្រាំលានរៀល ) និង ពីជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ: វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន ៦៨ លានរៀល ( ហុកសិបប្រាំបីលានរៀល ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងអប់រំ យុវជន និង កីឡា " ផ្នែក យុវជន និង កីឡា "សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១៨០ លានរៀល ( មួយរយប៉ែតសិបលានរៀល ) ពីជំពូក ៣១ ( អន្តរាគម៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ១៦៦ លានរៀល ( មួយរយហុកសិបប្រាំមួយលានរៀល ) និង ជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន ១៤ លានរៀល ( ដប់បួនលានរៀល ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងអប់រំ យុវជន និង កីឡា " ផ្នែក អប់រំ "សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា៣:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១២៤ លានរៀល ( មួយរយម្ភៃបួនលានរៀល ) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងអប់រំ យុវជន និង កីឡា " ផ្នែក ឧត្តមសិក្សា " សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា៤:** ការបែងចែកឥណទានថវិកា ចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ប្រាក់បៀវត្សដែលខ្វះក្នុងឆ្នាំ ២០០១។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងតម្លើងឋានន្តរសក្តិនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## ស ំ រ េ ច

__មាត្រា១__ : ត្រូវបានតែងតាំងតម្លើងឋានន្តរសក្តិ ថ្នាក់វរសេនីយ៍ឯក និងថ្នាក់វរនាវីឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

### ក- តម្លើងឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯក

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | ជួន | សុត | អត្តលេខ ០០១៣១៦ | នាយការិយាល័យហិរញ្ញវត្ថុ ខុទ្ទកាល័យក្រសួងការពារជាតិ |
| ២-វរសេនីយ៍ទោ | ខៀវ | ប៊ុនធឿន | អត្តលេខ ០០៩៦០០ | នាយការិយាល័យសណ្តាប់ធ្នាប់ ខុទ្ទកាល័យក្រសួងការពារជាតិ |
| ៣-វរសេនីយ៍ទោ | ម៉ម | ប៊ុនថន | អត្តលេខ ០១៤៦៧៨ | នាយការិយាល័យភ័ស្តុភារ ខុទ្ទកាល័យក្រសួងការពារជាតិ |
| ៤-វរសេនីយ៍ទោ | សេក | សេង | អត្តលេខ ០០១៤៤១ | លេខាឯកឧត្តម ទាយ ស៊ាំងយុន រដ្ឋលេខាធិការ ក្រសួងការពារជាតិ |

| | | | |
|---|---|---|---|
| ៥-វរសេនីយ៍ទោ | សឿន ឿន | អត្តលេខ ០០១៧២១ | នាយការិយាល័យផែនការ នាយកដ្ឋានវិស្វកម្ម |
| ៦-វរសេនីយ៍ទោ | អ៊ុន ប៊ុនសី | អត្តលេខ ០០១៧២៣ | នាយការិយាល័យសំណង់អាគារ នាយកដ្ឋានវិស្វកម្ម |
| ៧-វរសេនីយ៍ទោ | ប៊ុល សាគុណ | អត្តលេខ ០០១៧៥៨ | នាយការិយាល័យបច្ចេកទេស នាយកដ្ឋានវិស្វកម្ម |
| ៨-វរសេនីយ៍ទោ | អាដ្រ ចាន់មុន្នី | អត្តលេខ ០០១៩៤១ | នាយលេខាធិការដ្ឋាន នាយកដ្ឋានហិរញ្ញវត្ថុ |
| ៩-វរសេនីយ៍ទោ | ព្រុំ សត្ថារដ្ឋ | អត្តលេខ ០០១៧៧៣ | នាយការិយាល័យបច្ចេកទេស នាយកដ្ឋានសុខាភិបាល |
| ១០-វរសេនីយ៍ទោ | ស៊ីរ៉ា គាត់តេី | អត្តលេខ ០០១១៥៨ | បច្ចុប្បន្នជា នាយករង នាយកដ្ឋានវិស្វកម្ម |
| ១១-វរសេនីយ៍ទោ | នួច សុខឈរិទ្ធ | អត្តលេខ ០១៧៣៧៤ | នាយការិយាល័យភ័ស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានយោធសេវា |
| ១២-វរសេនីយ៍ទោ | កែវ សារុណ | អត្តលេខ ០០១៦៩០ | នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋានយោធសេវា |
| ១៣-វរសេនីយ៍ទោ | យ៉ាវ ចោមដេវី | អត្តលេខ ០០១៦៨៤ | នាយការិយាល័យសោតទស្សន៍បោះពុម្ពផ្សាយ អគ្គនាយកដ្ឋានយោធសេវា |
| ១៤-វរសេនីយ៍ទោ | គីម សុខណ្ឌ | អត្តលេខ ០០១៤៧៣ | នាយលេខាធិការដ្ឋាន បច្ចុប្បន្នជា នាយករង នាយកដ្ឋានកិច្ចការយោធាស៊ីវិល |
| ១៥-វរសេនីយ៍ទោ | អៀត សុតិ | អត្តលេខ ០០១៣៨៧ | នាយលេខាធិការដ្ឋាន នាយកដ្ឋាននយោបាយផែនការ |
| ១៦-វរសេនីយ៍ទោ | សៅ សុផាត | អត្តលេខ ០០១៣៨៨ | នាយការិយាល័យសេវាសង្គម នាយកដ្ឋាននយោបាយផែនការ |
| ១៧-វរសេនីយ៍ទោ | ទីន ណារិទ្ធសម្បត្តិ | អត្តលេខ ០០១៣៨៤ | នាយការិយាល័យអាំងហ្វម៉ាទិក នាយកដ្ឋាននយោបាយផែនការ |
| ១៨-វរសេនីយ៍ទោ | ខែត យូសឹផល | អត្តលេខ ០០១៩៤៤ | នាយភ័ស្តុភារហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ១៩-វរសេនីយ៍ទោ | មួន សារឿន | អត្តលេខ ០០១៩៨៧ | នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |

២០-វរសេនីយ៍ទោ ខាន់ ប៊ុនធឿន អត្តលេខ ០០១៩៦៧ នាយការិយាល័យសញ្ញាវុធ នាយកដ្ឋានបច្ចេកទេស

២១-វរសេនីយ៍ទោ ខៀវ ចន្ធារិទ្ធ អត្តលេខ ០០២២៤៩ នាយករងសាលាជំនាញឯកទេសចំរុះ

២២-វរសេនីយ៍ទោ នន ថាស់ អត្តលេខ ០០១៩៥៦ នាយការិយាល័យផែនការ នាយកដ្ឋានបច្ចេកទេស

២៣-វរសេនីយ៍ទោ សាខ ទូឌី អត្តលេខ ០១០៩២៩ នាយការិយាល័យរថយន្តម៉ាស៊ីន នាយកដ្ឋានបច្ចេកទេស

២៤-វរសេនីយ៍ទោ ប៊ុន អៀវិស អត្តលេខ ០០១៩៤៩ នាយការិយាល័យរថក្រោះរថពាសដែក នាយកដ្ឋានបច្ចេកទេស

២៥-វរសេនីយ៍ទោ ហខ្សូ ប៊ុនធ្លេខ អត្តលេខ ០១៣៩០៨ នាយអង្គភាពឃ្លាំសញ្ញាវុធ កា៥ នាយកដ្ឋានបច្ចេកទេស

២៦-វរសេនីយ៍ទោ ខឹម សំអូន អត្តលេខ ០០៩៥៩៥ នាយលេខាធិការដ្ឋាន នាយកដ្ឋានបំពាក់សំភារៈសឹក

២៧-វរសេនីយ៍ទោ ញ៉ៀប ចិន្តាសត្ថិ អត្តលេខ ០១៨៥៨២ នាយការិយាល័យគ្រប់ខ័ណ្ឌបំពាក់ នាយកដ្ឋានបំពាក់សំភារៈសឹក

២៨-វរសេនីយ៍ទោ អ៊ិន សយ អត្តលេខ ០១៧២៣៤ នាយការិយាល័យគ្រប់គ្រងប្រគពជំនួយ នាយកដ្ឋានបំពាក់សំភារៈសឹក

២៩-វរសេនីយ៍ទោ ឌៀប ផាន់ណា អត្តលេខ ០០២១៩៩ នាយការិយាល័យគ្រប់គ្រងនិងបណ្តុះបណ្តាលជំនាញឯកទេស នាយកដ្ឋានបំពាក់សំភារៈសឹក

៣០-វរសេនីយ៍ទោ វ៉ែន ឆៅ អត្តលេខ ០០៨៤៣០ នាយអង្គភាពឃ្លាំង កា៨៦ នាយកដ្ឋានបច្ចេកទេស

៣១-វរសេនីយ៍ទោ អ៊ុក ហួច អត្តលេខ ០០១៦៦៣ នាយលេខាធិការដ្ឋាន នាយកដ្ឋានបញ្ជូនសារ

៣២-វរសេនីយ៍ទោ មេខ សុត្ថារិទ្ធ អត្តលេខ ០០៣៦៩៤ នាយការិយាល័យផែនការ នាយកដ្ឋានបញ្ជូនសារ

៣៣-វរសេនីយ៍ទោ ហឿខ គុជច័ន្ទតារ៉ា អត្តលេខ ០០១៦៧៣ នាយការិយាល័យបច្ចេកទេស នាយកដ្ឋានបញ្ជូនសារ

៣៤-វរសេនីយ៍ទោ គាត់ សុភារា អត្តលេខ ០០១៩៦០ នាយការិយាល័យសំភារៈ នាយកដ្ឋានបច្ចេកទេស

៣៥ វរសេនីយ៍ទោ សុខ ខេមរដ្ឋ អត្តលេខ ០០៣៨៣៦ នាយបុគ្គលិក វិទ្យាស្ថានយោធាកម្ពុជា

៤

| | | | | |
|---|---|---|---|---|
| ៣៦-វរសេនីយ៍ទោ | គីម | ខណ្ឌសារ៉ុម | អត្តលេខ ០០៧២៤០ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺន បញ្ជាការ-សេនាធិការ វិទ្យាស្ថានយោធាកម្ពុជា |
| ៣៧-វរសេនីយ៍ទោ | គាយ | វយោហា | អត្តលេខ ០០១៦៣៨ | នាយការិយាល័យផែនការនាយកដ្ឋានទាក់ទងអន្តរជាតិ |
| ៣៨-វរសេនីយ៍ទោ | តើត | ណាឌិន | អត្តលេខ ០០១៦៣៩ | នាយលេខាធិការដ្ឋាន នាយកដ្ឋានទាក់ទងអន្តរជាតិ |
| ៣៩-វរសេនីយ៍ទោ | ខៀវ | សាផាត | អត្តលេខ ០០១៤០៣ | នាយការិយាល័យបណ្តុះបណ្តាល នាយកដ្ឋានបុគ្គលិក |
| ៤០-វរសេនីយ៍ទោ | ឡេង | សុផុន | អត្តលេខ ០០១៤១១ | នាយការិយាល័យគ្រប់គ្រងទាហានបំរុង នាយកដ្ឋានបុគ្គលិក |
| ៤១-វរសេនីយ៍ទោ | ឃីម | ថាវី | អត្តលេខ ០០១៤១០ | នាយការិយាល័យគ្រប់គ្រងបុគ្គលិកស៊ីវិល នាយកដ្ឋានបុគ្គលិក |
| ៤២-វរសេនីយ៍ទោ | ឈឹម | សុផាន់ | អត្តលេខ ០០១៤២០ | នាយការិយាល័យគ្រប់គ្រងឯកសារ នាយកដ្ឋានបុគ្គលិក |
| ៤៣-វរសេនីយ៍ទោ | ថោង | ចាន់ណា | អត្តលេខ ០០១៤២៤ | នាយការិយាល័យគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ នាយកដ្ឋានបុគ្គលិក |
| ៤៤-វរសេនីយ៍ទោ | ធន | សុខេង | អត្តលេខ ០០១៤០៦ | នាយលេខាធិការដ្ឋាន នាយកដ្ឋានបុគ្គលិក |
| ៤៥-វរសេនីយ៍ទោ | សុខ | ប៊ុនថន | អត្តលេខ ០០១៤០៧ | នាយការិយាល័យអាំងហ្វូម៉ាទិក នាយកដ្ឋានបុគ្គលិក |
| ៤៦-វរសេនីយ៍ទោ | ហ៊ឹម | ណារិន | អត្តលេខ ០០៤៥២៤ | មេបញ្ជាការរង ទទួលបន្ទុកប្រតិបត្តិការនិងហ្វឹកហ្វឺន កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ |
| ៤៧-វរសេនីយ៍ទោ | គីម | សាឃួន | អត្តលេខ ០០៤៥២៥ | នាយផ្នែកយន្តហោះស្លាប កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ |
| ៤៨-វរសេនីយ៍ទោ | ញ៉ឹក | សមីយ | អត្តលេខ ០០៣២៤៤ | នាយករង ទីចាត់ការបំភ័ន្តអក្ខរៈ អគ្គបញ្ជាការដ្ឋាន |
| ៤៩-វរសេនីយ៍ទោ | យុត | ស៊ុនហេង | អត្តលេខ ០០២១៩៨ | នាយករង ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន |
| ៥០-វរសេនីយ៍ទោ | យុន | គេង | អត្តលេខ ០០២២០៤ | នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន |

៥១-វរសេនីយ៍ទោ មាស ទ៉ាន់រ៉េន អត្តលេខ ០០២២០៥ នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *កាលប្បវត្តិ-ឯកសារ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៧៥ សសរ...

# សេចក្តីសំរេច

## ស្តីពី

## ការប្តូរប្រធានគណៈកម្មាការអន្តរក្រសួង ដើម្បីដោះស្រាយសំរបសំរួលជាមួយប្រជាពលរដ្ឋដែលកាន់កាប់ដីធ្លីបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ/បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ
- បានឃើញសេចក្តីសំរេចលេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរអប្សរា

## សំរេច

**ប្រការ ១ .—**

តែងតាំងឯកឧត្តម ញាន ឡេខ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធានគណៈកម្មាការអន្តរក្រសួង ជំនួសឯកឧត្តម អ៊ុត ឈន ដែលត្រូវបានបំពេញភារកិច្ចថ្មី ។

**ប្រការ ២ .—**

សមាសភាពដទៃទៀត ដែលមាននៅក្នុងសេចក្តីសំរេច លេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ត្រូវរក្សាទុកដដែល ។

**ប្រការ ៣ .—**

ភារកិច្ច និងខ្លឹមសារនៃសេចក្តីសំរេច លេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ដែលមានចែងក្នុង ប្រការ ៣ ប្រការ ៤ និង ប្រការ ៥ ត្រូវបានរក្សាទុកដដែល ។

**ប្រការ ៤ .—**

ទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមប្រឹក្សាអ្នកច្បាប់ ខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង ប្រការ ១ និង ប្រការ ២ មានភារកិច្ចអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៨ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៨ ស.រ.ណ.ន

## សារាចរណែនាំ

## ស្តីពី

## ការពង្រឹង និងជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងសភាពការណ៍ថ្មី

ទេសចរណ៍គឺជាវិស័យអាទិភាពមួយក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ។ ប៉ុន្មានឆ្នាំចុងក្រោយនេះចំនួនភ្ញៀវទេសចរមកដល់កម្ពុជាមានបរិមាណកើនឡើងពី ២៥%-៣០% ដែលនាំឱ្យវិស័យទេសចរណ៍កម្ពុជាយើងបានបង្ហាញនូវតួនាទីពិតប្រាកដក្នុងការនាំមកនូវចំណូលជាតិ និងបង្កើនការងារជូនប្រជាពលរដ្ឋរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។

ដោយព្រឹត្តិការណ៍ភេរវកម្មថ្ងៃទី១១ ខែកញ្ញា នៅទីក្រុងញូយ៉ក និងវ៉ាស៊ីងតោនសហរដ្ឋអាមេរិកបានជះឥទ្ធិពលប្រែប្រួលផ្ទាល់ដល់កំណើនទេសចរណ៍ពិភពលោក ហើយបានប៉ះពាល់មួយចំណែកដល់កំណើនទេសចរណ៍នៅប្រទេសកម្ពុជា ប៉ុន្តែបច្ចុប្បន្នស្ថានការណ៍ទេសចរណ៍កំពុងតែវិលត្រឡប់ជាបណ្តើរៗមកកាន់សភាពដើមវិញហើយ។

ដោយកម្ពុជាយើងជាប្រទេសមួយសម្បូរណ៍ទៅដោយសក្តានុពលវប្បធម៌-ធម្មជាតិ មានអច្ឆរិយៈវត្ថុពិភពលោក សំរាប់ទាក់ទាញភ្ញៀវទេសចរដែលភាគច្រើនកំពុងមាននិន្នាការផ្តោតទៅលើទេសចរណ៍បែបវប្បធម៌និងធម្មជាតិ, ស្របនឹងប្រទេសយើងកំពុងស្ថិតក្នុងសន្តិភាព និងស្ថេរភាពនយោបាយពេញលេញផងកម្ពុជាត្រូវត្រៀមលក្ខណៈសមស្របដើម្បីពង្រឹង និងជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងសភាពការណ៍ថ្មីឱ្យរក្សាបានកំណើនកាន់តែប្រសើរឡើងថែមទៀត

**រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖**

១- អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ធ្វើការសម្របសម្រួលនិងសហការណ៍ជាមួយ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពត៌មាន និងអាជ្ញាធរអប្សរា ពិគ្រោះពិភាក្សាគ្នាអំពី៖

- គោលដៅទេសចរណ៍ជាអាទិភាព និងសុវត្ថិភាពសំរាប់ភ្ញៀវទេសចរ
- លទ្ធភាពបង្កើតសកម្មភាពសង្គម និងការកំសាន្តសំរាប់បំពេញបន្ថែមកម្មវិធីរបស់ភ្ញៀវទេសចរមានជាអាទិ៍សិល្បៈ ទស្សនីយភាព របាំ ល្បែងប្រជាប្រិយ និងកីឡា។ល។
- ជំរុញការឃោសនាផ្សព្វផ្សាយតាមគ្រប់មធ្យោបាយនិងគ្រប់រូបភាព ដើម្បីទាក់ទាញ លើកទឹកចិត្តភ្ញៀវទេសចរ។

២- ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវយកចិត្តទុកដាក់ និងចាត់វិធានការជាបន្ទាន់លើបែបបទផ្តល់ទិដ្ឋាការដល់ភ្ញៀវទេសចរនៅគ្រប់ច្រកទ្វារអន្តរជាតិ ទាំងផ្លូវអាកាស ផ្លូវគោក ផ្លូវទឹក ធ្វើយ៉ាងណាឱ្យបានឆាប់រហ័ស តែក្នុងស្មារតីពង្រឹងសន្តិសុខនិងសុវត្ថិភាព។ ទន្ទឹមនឹងនេះត្រូវសហការណ៍ជាមួយអាជ្ញាធរអាកាសចរស៊ីវិល កងរាជអាវុធហត្ថជាតិលើផ្ទៃប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ទីចាត់ការគយនិងរដ្ឋាករ) ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល), អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវពង្រឹងបង្កើននូវតួនាទីសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងផ្តល់ភាពងាយស្រួលក្នុងការត្រួតពិនិត្យឆ្លងកាត់របស់ភ្ញៀវទេសចរ ពិសេសនៅតាមច្រកទ្វារអន្តរជាតិទាំងអស់ និងតាមមណ្ឌលកំសាន្តនានាឱ្យបានហ្មត់ចត់ល្អ ត្រូវចៀសវាងជាដាច់ខាតនូវការធ្វើឱ្យតឹងតែងលើសពីពង្រឹងសន្តិសុខបង្កភាពលំបាកដល់ដំណើរមកដល់នៃភ្ញៀវទេសចរ។

៣- ក្រសួងទេសចរណ៍ត្រូវខិតខំបង្កើនឱ្យបានខ្លាំងក្លានូវគុណភាពសេវាកម្មទេសចរណ៍ទាំងឡាយរួមទាំងការថែរក្សាអនាម័យ សណ្តាប់ធ្នាប់ ផ្លាកសញ្ញាពត៌មាន នៅតាមរមណីយដ្ឋានទេសចរណ៍ និងមណ្ឌលកំសាន្តនានាឱ្យបានប្រសើរ។ ទន្ទឹមនឹងនេះត្រូវបង្កើតកម្មវិធីយល់ដឹងអំពីសារៈប្រយោជន៍ទេសចរណ៍ដល់ប្រជាពលរដ្ឋ, ចូលរួមចំណែកធ្វើបដិសណ្ឋារកិច្ច និងផ្តល់នូវភាពស្វាគមន៍ជូនភ្ញៀវឱ្យបានល្អដោយរក្សានូវប្រពៃណីខ្មែរ។ អាជ្ញាធរអប្សរាត្រូវខិតខំរៀបចំបង្កើនគុណភាពសេវាកម្មដូចខាងលើនៅក្នុងតំបន់ឧទ្យានអង្គររួមទាំងភោជនីយដ្ឋាន សំណាក់ សេវាសុខាភិបាល សេវាទូរគមនាគមន៍ និងជំរុញអនុវត្តឱ្យជោគជ័យផែនការសកម្មភាពទាំងឡាយដែលបានគ្រោងទុក។

៤- ក្រសួង ស្ថាប័នពាក់ព័ន្ធទាំង៣ប្រភេទខាងលើត្រូវពង្រឹងការអនុវត្តអនុក្រឹត្យលេខ ៦៤អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពី ការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ត្រូវយកចិត្តទុកដាក់ដល់ការកែសម្រួល

៤

រចនាសម្ព័ន្ធ និងមូលដ្ឋានសំភារៈ សំរួលដល់បែបបទធ្វើដំណើរ ពិសេសអាគារអ្នកដំណើរនៅច្រកទ្វារអន្តរជាតិ ពោធិ៍ចិនតុង សៀមរាប ប៉ោយប៉ែត បាវិត ជាបន្ទាន់។

៥_ ក្រសួងសាធារណការនិងដឹកជញ្ជូន កងវិស្វកម្មយោធពលខេមរភូមិន្ទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខេត្ត-ក្រុង ត្រូវជំរុញការស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទៅកាន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានអាទិភាពសំខាន់ៗទាំងឡាយតាមគ្រប់លទ្ធភាពទាំងអស់ ហើយត្រូវប្រមូលផ្តុំយកចិត្តទុកដាក់ជួយដល់អាជ្ញាធរខេត្តសៀមរាប អាជ្ញាធរអប្សរា ក្នុងការជួសជុលថ្នល់ការដាក់ភ្លើងបំភ្លឺ (ព្រលានយន្តហោះ-ក្រុងសៀមរាប-អង្គរវត្ត) និងសេវាទូរគមនាគមន៍សាធារណៈក្នុងក្រុងសៀមរាប និងតំបន់អង្គរឱ្យបានឆាប់រហ័ស។

៦_ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា សម្របសម្រួលនិងសហការណ៍ជាមួយ ក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជនពិគ្រោះពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអំពី÷

- ចលនាជម្រុញក្រុមហ៊ុនវិនិយោគដែលមានចំណូលផ្ទាល់ពីវិស័យទេសចរណ៍ មានជាអាទិ៍ក្រុមហ៊ុនគ្រប់គ្រងព្រលានយន្តហោះ ក្រុមហ៊ុនទទួលលក់សំបុត្រចូលទស្សនាប្រាសាទ ឱ្យរួមចំណែកក្នុងការឃោសនាទាក់ទាញភ្ញៀវទេសចរពីក្រៅប្រទេសចំពោះមុខសញ្ញាទីផ្សារជាអាទិភាពនានា ឬរួមចំណែកបន្ថយអប្បរមានៃចំណាយរបស់ភ្ញៀវ។
- យុទ្ធសាស្ត្រជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើតសហគ្រាសតូច-មធ្យមបំរើវិស័យទេសចរណ៍។

៧_ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវយកចិត្តទុកដាក់÷

- រៀបចំគាំពារស្តារប្រាសាទ, ជួសជុលរូបបដិមាករ និងប្រព័ន្ធរចនាបទក្បាច់បេតិកភ័ណ្ឌ និងកែលំអ បរិស្ថានវប្បធម៌ ទាំងឡាយណាដែលស្ថិតក្រៅតំបន់គ្រប់គ្រងរបស់អាជ្ញាធរអប្សរា,
- កែសម្រួលកម្មវិធីចូលទស្សនាសារមន្ទីរ និងរៀបចំសំដែងសិល្បៈទស្សនីយភាពជូនភ្ញៀវទស្សនា,
- ពង្រឹងការគ្រប់គ្រងមូលដ្ឋានសិប្បកម្មផលិតនិងលក់ដូរវត្ថុអនុស្សាវរីយ៍សិល្បៈវប្បធម៌នៅគ្រប់តំបន់អាទិភាពនៃគោលដៅទេសចរណ៍។

៨_ ដើម្បីអនុវត្តកិច្ចការនេះឱ្យមានប្រសិទ្ធិភាព អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា ត្រូវសម្របសម្រួល និងសហការរៀបចំយុទ្ធនាការពិសេសមួយ ដែលត្រូវមានការចូលរួម និងគាំទ្រពីគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ និងផ្នែកឯកជនពាក់ព័ន្ធទាំងអស់។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានទទួលលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ សសរ

# លិខិតបញ្ជា
## ស្តីពី
## វិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

---

កន្លងមក រាជរដ្ឋាភិបាល បានចេញជាបន្តបន្ទាប់នូវ អនុក្រឹត្យ លិខិតបញ្ជា ឬសារាចរណែនាំនានាមួយចំនួន ក្នុងគោលបំណង ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងកែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ពាក់ព័ន្ធនឹងកិច្ចសហការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ តាមគ្រប់រូបភាព មានជាអាទិ៍ : លិខិតបញ្ជាលេខ ២៣លប ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីវិធានការទប់ស្កាត់អំពើរត់គេចពន្ធ នៅតាមច្រក ចេញ-ចូល ព្រំដែន សារាចរលេខ ០៦សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យលេខ ៦៤អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប៉ុន្តែរាជរដ្ឋាភិបាល ក៏បានសង្កេតឃើញថា ប្រសិទ្ធភាពនៃការទប់ស្កាត់ និងការបង្ក្រាបអំពើរត់គេចពន្ធ ពុំទាន់ត្រូវបានបង្កើនឱ្យអស់លទ្ធភាពនៅឡើយ ។ ក្រៅពីធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ដល់ចំណូលថវិការដ្ឋ អំពើរត់គេចពន្ធ បានធ្វើឱ្យមានអំពើអយុត្តិធម៌ក្នុងការប្រកួតប្រជែងពាណិជ្ជកម្មថែមទៀត ។ ហេតុនេះ វាគឺជាកម្មវត្ថុដ៏ក្តៅគគុក ក្នុងក្រសែភ្នែកមហាជន ធុរជន វិនិយោគិន ក៏ដូចជាសហគមន៍អ្នកផ្តល់ជំនួយ និងបណ្តាអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិនានាផងដែរ នាពេលបច្ចុប្បន្ននេះ ។

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ រាជរដ្ឋាភិបាលចេញបទបញ្ជាដូចខាង ក្រោម :

១- កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធ មានកាតព្វកិច្ច ត្រូវគាំទ្រ និងចូលរួមសហការយ៉ាងសកម្មបំផុត ប្រកបដោយភាពស្មោះស្ម័គ្រ និងទាន់ពេលវេលាជាមួយសមត្ថកិច្ចគយ និងរដ្ឋាករ ក្នុងការអនុវត្តន៍ការងារស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ នៅរាល់ពេលដែលសមត្ថកិច្ចនេះ ស្នើសុំការគាំទ្រ និងការចូលរួមសហការជាផ្លូវការ ដោយចៀសវាងការលូកដៃធ្វើកិច្ចការរបស់សមត្ថកិច្ចគយ និងរដ្ឋាករ ដោយផ្ទាល់ ។ សមត្ថកិច្ចគយ និងរដ្ឋាករ ត្រូវធ្វើទំនាក់ទំនងចំហរជាផ្លូវការជាមួយអង្គភាពមានសមត្ថកិច្ចពាក់ពន្ធ័

ដែលត្រូវចូលរួមធ្វើប្រតិបត្តិការ ជៀសវាងការធ្វើទំនាក់ទំនងជាបុគ្គល ។ កិច្ចប្រតិបត្តិការនេះ ត្រូវដំណើរការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានលក្ខណៈច្បាស់លាស់ ស្របតាមទ្រង់ទ្រាយ ទំហំ និងភាពចាំបាច់នៃករណីនីមួយៗ ដោយចែកចេញជាបីប្រភេទ ដូចខាងក្រោម :

១.១- **ប្រភេទទី ១** : គឺជាប្រភេទប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធទ្រង់ទ្រាយធំ ប្រកបដោយការត្រៀមទប់ទល់ និងមានការចាត់តាំងជាខ្សែរយៈគ្រោងទុកជាមុន ដែលអាជ្ញាធរគយ និងរដ្ឋាករ ត្រូវការការគាំទ្រ និងការចូលរួមសហការពីកំលាំងសរុបអន្តរក្រសួង ។ ប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធប្រភេទទី ១ នេះ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មការអន្តរក្រសួងមួយដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម | **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជា សារ៉ា** | នាយរងសេនាធិការចំរុះនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៤- ឯកឧត្តមឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥- ឯកឧត្តមឧត្តមសេនីយ៍ទោ | **នេត សាវឿន** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ៦- ឯកឧត្តម | **ហួ ទីចិត្រ** | អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ៧- លោក | **ស៊ុត សារ៉ា** | ប្រធាននាយកដ្ឋានកាំកុងត្រូល | សមាជិក |
| ៨- លោក | **ស ថេង** | ប្រធានការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធនៃទីចាត់ការគយ និងរដ្ឋាករ | សមាជិក ។ |

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់កងកំលាំងប្រដាប់អាវុធ និងមធ្យោបាយការងារនានា ដែលស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាមីពាក់ព័ន្ធតាមទំហំសមស្របមួយ ដោយមានការឯកភាពពីប្រធាន តាមការស្នើសុំពីអនុប្រធានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ភារកិច្ចរបស់គណៈកម្មការអន្តរក្រសួងនេះ រួមមាន :

- ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងដឹកនាំការធ្វើប្រតិបត្តិការបង្ក្រាបអំពើល្មើសរត់គេចពន្ធទំនិញគ្រប់ប្រភេទ ដែលមានទ្រង់ទ្រាយធំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន

- ប្រជុំ ធ្វើការបូកសរុប និងវាយតំលៃចំណុចខ្លាំង ចំណុចខ្សោយនានានៃការអនុវត្តន៍នូវលិខិតបញ្ជានេះ

- ចាត់តាំង ផ្សព្វផ្សាយ និងជូនដំណឹង ឱ្យបានទូលំទូលាយដល់កំលាំងមានសមត្ថកិច្ចពាក់ព័ន្ធតាមមូលដ្ឋាន និងទីតាំងចាំបាច់នានាឱ្យបានយល់ដឹង និងស្គាល់កាតព្វកិច្ចរៀងៗខ្លួនក្នុងការចូលរួមសហការនេះ ជាអាទិ៍ ការបើកធ្វើសិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ ឬតាមរយៈការបោះពុម្ពចែកចាយនូវកំរងឯកសារច្បាប់ លិខិតបទដ្ឋាន និងបទបញ្ញត្តិ

ពាក់ព័ន្ធជាធរមាន ។

- លើកឡើងនូវបណ្ណាវិធានការពង្រឹងបន្ថែម និងកែលំអការអនុវត្តន៍តាមតំរូវការជាក់ស្តែង ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ លើទំនិញគ្រប់ប្រភេទ ឱ្យកាន់តែមានប្រសិទ្ធភាពឡើងជាលំដាប់

- រាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

១.២- **ប្រភេទទី ២ :** គឺជាប្រភេទប្រតិបត្តិការដែលមានទ្រង់ទ្រាយមធ្យម ប្រកបដោយការត្រៀមទុកជាមុន ដែលអាជ្ញាធរគយ និងរដ្ឋាករ ត្រូវការការគាំទ្រ និងការចូលរួមពីកំលាំងកងប្រដាប់អាវុធ ឬអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ តាមមូលដ្ឋាន ខេត្ត-ក្រុង ពាក់ព័ន្ធនីមួយៗ ។ ប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធ ដែលមានទ្រង់ទ្រាយមធ្យមនេះ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មការចំរុះតាមខេត្ត-ក្រុងនីមួយៗ ដែលមានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| ១- ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ឬអភិបាល ខេត្ត-ក្រុង | ប្រធាន |
| ២- ប្រធានសាខាគយ និងរដ្ឋាករ ខេត្ត-ក្រុង | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- មេបញ្ជាការកងរាជអាវុធហត្ថ ខេត្ត-ក្រុង | សមាជិក |
| ៤- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ខេត្ត-ក្រុង | សមាជិក |
| ៤- នាយស្នងការនៃស្នងការដ្ឋាននគរបាល ខេត្ត-ក្រុង | សមាជិក |
| ៥- ប្រធានសាខាកាំកុងត្រូល ខេត្ត-ក្រុង | សមាជិក |

ក្នុងករណីដែលប្រតិបត្តិការមានទ្រង់ទ្រាយមធ្យមនេះ ប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ឬតាមបណ្តា ខេត្ត-ក្រុង ដែលពុំទាន់មានសាខាគយ និងរដ្ឋាករ ប្រធានការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ នៃទីចាត់ការគយ និងរដ្ឋាករ ត្រូវទទួលជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការនេះ ។

គណៈកម្មការចំរុះនេះ មានសិទ្ធិប្រើប្រាស់កងកំលាំងប្រដាប់អាវុធ និងមធ្យោបាយការងារនានា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពសាមីពាក់ព័ន្ធ តាមទំហំសមស្របមួយ ដោយមានការឯកភាពពីប្រធាន តាមការស្នើសុំពីអនុប្រធានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រាររបស់សាលា ខេត្ត-ក្រុង សាមីនីមួយៗ ។

ភារកិច្ចរបស់គណៈកម្មការចំរុះតាម ខេត្ត-ក្រុង រួមមាន :

- ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងដឹកនាំការបង្ក្រាបអំពើល្មើសរត់គេចពន្ធ ទំនិញគ្រប់ប្រភេទ ដែលមានទ្រង់ទ្រាយមធ្យមតាមមូលដ្ឋាន ខេត្ត-ក្រុង សាមី ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន

- ប្រជុំ ធ្វើការបូកសរុប និងវាយតំលៃចំណុចខ្លាំង ចំណុចខ្សោយនានានៃការអនុវត្តន៍នូវលិខិតបញ្ជានេះ និងលើកវិធានការអនុវត្តបន្ត

- រាយការណ៍អំពីលទ្ធផលការងារ ដែលសំរេចបានជូនគណៈកម្មការអន្តរក្រសួងខាងលើ ដោយចំលងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រី ។

១.៣- **ប្រភេទទី ៣ :** គឺជាប្រភេទប្រតិបត្តិការស្រាវជ្រាវ ពួនស្ទាក់ជាលក្ខណៈបន្ទាន់បំផុតក្នុងការតាមដានប្រកិតជាលក្ខណៈបទល្មើសជាក់ស្តែង និងការដេញចាប់ភ្លាម ដែលអាជ្ញាធរគយ និងរដ្ឋាករ ត្រូវការការចូលរួម

គាំទ្រ និងសហការជាបន្ទាន់បំផុត ពីកងកំលាំងប្រដាប់អាវុធគ្រប់អង្គភាព ឬអាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ដែលកំពុងឈរជើងបំពេញភារកិច្ច ឬកំពុងស្ថិតនៅក្នុងទីជិតបំផុតនៃកន្លែងកើតហេតុនីមួយៗ ។ កងកំលាំង ប្រដាប់អាវុធ ឬអាជ្ញាធរដែនដីមានកាតព្វកិច្ចត្រូវគាំទ្រ និងចូលរួមសហការជាបន្ទាន់តាមការស្នើសុំនេះ ដោយពុំចាំបាច់រង់ចាំការអនុញ្ញាត ឬបទបញ្ជាណាផ្សេងក្រៅពីលិខិតស្នើសុំការគាំទ្រ និងសហការជាផ្លូវការរបស់ទីចាត់ការគយ និងរដ្ឋាករ ដែលនឹងកំណត់ដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- កងកំលាំងប្រដាប់អាវុធគ្រប់អង្គភាព អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដែលបានពិនិត្យឃើញនូវបទល្មើសគយជាក់ស្តែងនានា ត្រូវជូនដំណឹងជាបន្ទាន់ដល់សមត្ថកិច្ចគយ និងរដ្ឋាករ ដែលកំពុងឈរជើងបំពេញភារកិច្ច នៅកន្លែងជិតបំផុតនៃកន្លែងកើតហេតុ ដើម្បីសហការគ្នា ឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយដឹកជញ្ជូន និងទំនិញល្មើសនេះ និងចូលរួមធ្វើកំណត់ហេតុល្មើសច្បាប់គយ តាមទំរង់ និងនីតិវិធីជាធរមាន ។ ដោយឡែកទំនិញ និងមធ្យោបាយដឹកជញ្ជូន ត្រូវចាត់ចែងបញ្ជូនជាបន្ទាន់ តាមដែលអាចធ្វើទៅបាន ទៅកាន់ការិយាល័យគយ និងរដ្ឋាករដែលនៅជិតបំផុត ដើម្បីថែរក្សា គ្រប់គ្រង រង់ចាំការសំរេចវិនិច្ឆ័យតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ទីចាត់ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុករ៉ាប់រងនូវការចំណាយចាំបាច់នានា ក្នុងប្រតិបត្តិការនីមួយៗ ក៏ដូចជាការចំណាយសំរាប់ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តផ្សេងៗ ចំពោះប្រតិបត្តិករ ដែលបានចូលរួម ដោយមានសិទ្ធិប្រើប្រាស់ទឹកប្រាក់នៃផលដែលបានមកពីប្រតិបត្តិការបង្ក្រាបនីមួយៗ ដែលត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្នុងករណីទឹកប្រាក់ដែលត្រូវផ្តល់រង្វាន់លើសពី ១០០លានរៀល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសុំយោបល់សំរេចពីប្រមុខរាជរដ្ឋាភិបាល ។

ទទួលបានលិខិតបញ្ជានេះ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនៃអគ្គនាយកដ្ឋាននគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ អភិបាល ខេត្ត-ក្រុង និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសំរេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង-រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលា ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៣៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់ ស្លាកយីហោរបស់ ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសារធានារ៉ាប់រង

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

## សម្រេច

**ប្រការ ១.-**

អនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រងបុគ្គលទាំងឡាយដែលអាចប្រកបអាជីវកម្មធានារ៉ាប់រងបានរួមមាន ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

**ប្រការ ២.-**

ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងដែលបានទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជាត្រូវប្រើប្រាស់ "ស្លាកយីហោ" ក្រុមហ៊ុនឱ្យបានត្រឹមត្រូវតាមអាជ្ញាប័ណ្ណដែលបានផ្តល់ជូនទោះនៅទីស្នាក់ការក្រុមហ៊ុន ឬនៅលើឯកសារដែលត្រូវចែកផ្សាយដល់សាធារណជន និងតាមរយៈការផ្សាយពាណិជ្ជកម្មផ្សេងៗ ។

**ប្រការ ៣.-**

ចំពោះក្រុមហ៊ុនដែលជាភ្នាក់ងារធានារ៉ាប់រង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅពីមុខ ឬ នៅពីក្រោយ ឬ នៅពីក្រោមឈ្មោះក្រុមហ៊ុននូវពាក្យថា "ភ្នាក់ងារធានារ៉ាប់រង" ។

ក្នុងករណីដែលមិនបានបញ្ជាក់ច្បាស់នូវពាក្យថា "ភ្នាក់ងារធានារ៉ាប់រង" នៅតាមទីកន្លែងដូចបានលើកឡើងនៅវាក្យខ័ណ្ឌទី១នៃប្រការនេះទេ ចាត់ទុកថាសាមីក្រុមហ៊ុនភ្នាក់ងារនោះមានចេតនាក្លែងបន្លំឯកសារដើម្បីធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ។

**ប្រការ ៤.-**

ចំពោះក្រុមហ៊ុនដែលជាជើងសាធានារ៉ាប់រង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ជាមួយនឹងឈ្មោះក្រុមហ៊ុននូវពាក្យថា "ជើងសាធានារ៉ាប់រង" ។

ក្នុងករណីដែលមិនបានបញ្ជាក់ច្បាស់នូវពាក្យថា " ជើងសាធានារ៉ាប់រង " នេះទេ ចាត់ទុកថាសាមីក្រុមហ៊ុនជើងសានោះ មានចេតនាក្លែងបន្លំឯកសារដើម្បីធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ។

**ប្រការ ៥.-**

ក្នុងករណីមានក្រុមហ៊ុនណាមួយ ប្រើប្រាស់ស្លាកយីហោក្រុមហ៊ុនមិនបានត្រឹមត្រូវតាមអាជ្ញាប័ណ្ណដែលបានផ្តល់ជូនទេ ទោះបីក្នុងកាលៈទេសៈណាក៏ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់វិធានការសមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានចំពោះសាមីក្រុមហ៊ុននោះ ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.-

ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៣៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការកំណត់ទូទៅ

## ចំពោះប្រតិបត្តិការធានារ៉ាប់រង

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

**សំរេច**

**ប្រការ ១.-**

អនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ប្រតិបត្តិករដែលអាចធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជារួមមាន ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

**ប្រការ ២.-**

ប្រតិបត្តិករធានារ៉ាប់រងទាំងអស់ មិនអាចធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជាបានទេប្រសិនបើ ÷

ក/ មិនមានអាជ្ញាប័ណ្ណ និងមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់សំរាប់ប្រភេទធានារ៉ាប់រងណាមួយ ឬទាំងពីរប្រភេទ ។

ខ/មិនបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវលិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានដាក់ប្រាក់តំកល់ចំនួនស្មើ នឹង១០(ដប់) ភាគរយនៃដើមទុនចុះបញ្ជីនៅរតនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជាទេ ។

គ/ មិនបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវលិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានរក្សាទុកទឹកប្រាក់ជាកំរិតសាធនភាពមិនតិចជាង ៥០(ហាសិប) ភាគរយនៃដើមទុនចុះបញ្ជីនៅធនាគារពាណិជ្ជណាមួយ នៅព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិទេ ។

**ប្រការ ៣.-**

ក្នុងករណីដែលបុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយប្រកាសខ្លួនថាជាក្រុមហ៊ុនធានារ៉ាប់រងសំរាប់ប្រភេទធានារ៉ាប់រងណាមួយ ប៉ុន្តែតាមពិតបុគ្គល ឬក្រុមហ៊ុននោះមិនមានអាជ្ញាប័ណ្ណធានារ៉ាប់រង និងមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់សំរាប់ប្រភេទធានារ៉ាប់រងណាមួយទេ នោះនឹងត្រូវចោទប្រកាន់ពីបទរំលោភច្បាប់ ហើយបុគ្គល ឬក្រុមហ៊ុននោះនឹងត្រូវផ្តន្ទាទោស ដូចមានចែងនៅមាត្រា ៥៣ និងមាត្រា ៥៤នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

**ប្រការ ៤.-**

ក្រៅពីប្រតិបត្តិករធានារ៉ាប់រង ដែលបានចុះបញ្ជីត្រឹមត្រូវ និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ចនោះ មិនអាចមានបុគ្គលណាមានសិទ្ធិប្រើប្រាស់ពាក្យ "ធានារ៉ាប់រង" ឬពាក្យណាដែលក្លាយពីពាក្យនេះ ដែលបញ្ជាក់ថាបុគ្គលនោះ ប្រកបអាជីវកម្មធានារ៉ាប់រងដោយប្រើប្រាស់ស្លាកយីហោឬសិទ្ធិប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬធ្វើការប្រកាសណាមួយនៅលើសេចក្តីជូនដំណឹង ឬការផ្សាយពាណិជ្ជកម្មឡើយ ។

ប្រការ ៥.-

នៅពេលណាដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានហេតុផល និងភស្តុតាងគ្រប់គ្រាន់ថាក្រុមហ៊ុនណាមួយធ្វើអាជីវកម្មធានារ៉ាប់រងដោយគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវតាមច្បាប់ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចុះធ្វើការត្រួតពិនិត្យផ្ទាល់ដល់សាមីក្រុមហ៊ុន ដើម្បីឱ្យឃើញច្បាស់ថាក្រុមហ៊ុននោះបាន ឬ កំពុងបំពានគោលការណ៍ណាមួយនៃច្បាប់ស្តីពីការធានារ៉ាប់រង ។

ប្រការ ៦.-

នៅក្នុងរយៈពេលប្រាំមួយ (៦) ខែគិតចាប់ពីថ្ងៃបានទទួលអាជ្ញាប័ណ្ណ ប្រសិនបើសាមីក្រុមហ៊ុនធានារ៉ាប់រងមិនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មទៅតាមច្បាប់ដោយគ្មានមូលហេតុដែលអាចទទួលស្គាល់បានទេ អាជ្ញាប័ណ្ណរបស់ខ្លួននឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ។

ប្រការ ៧.-

កាលបើពិនិត្យឃើញថា ក្រុមហ៊ុនធានារ៉ាប់រងណាមួយស្ថិតនៅក្នុងស្ថានភាពមិនអាចផ្តល់ការធានាគ្រប់គ្រាន់ចំពោះកិច្ចសន្យារបស់ខ្លួន ឬមិនអាចរ៉ាប់រងបាននូវទំហំហានិភ័យ ដែលនឹងអាចកើតឡើងទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការរំលឹកដាស់តឿនជាលាយលក្ខណ៍អក្សរ និងបង្គាប់ដាច់ខាតឱ្យសាមីក្រុមហ៊ុនធានារ៉ាប់រង គូសវាសកម្មវិធីហិរញ្ញវត្ថុច្បាស់លាស់សំរាប់ស្តារក្រុមហ៊ុនរបស់ខ្លួនឱ្យមានប្រក្រតីភាពឡើងវិញ ។ ប្រសិនបើនៅតែគ្មានលទ្ធភាពស្តារបានតាមសេចក្តីបង្គាប់ដាច់ខាតខាងលើនេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិហាមឃាត់ក្រុមហ៊ុនសាមីប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជារហូតដល់មានការដោះស្រាយបានជាស្ថាពរ ។

ប្រការ ៨.-

អាជ្ញាប័ណ្ណដែលត្រូវបានផ្តល់ឱ្យក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង អាចនឹងត្រូវដកហូតមកវិញបានគ្រប់ពេលវេលា កាលបើក្រុមហ៊ុនណាមួយនោះ :

-មិនអាចបំពេញគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌដែលតំរូវឱ្យអនុវត្តតាម

-មិនអាចធ្វើឱ្យបានសំរេចក្នុងរយៈពេលដែលបានយល់ព្រមចំពោះវិធានការគ្រោងទុកទាំងឡាយ តាមកម្មវិធីកែតម្រង់ឡើងវិញ

-ឬមួយមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងការបំពេញកាតព្វកិច្ច ដែលតម្រូវដោយបទបញ្ជាជាធរមាន ។

**ប្រការ ៩.-**

សាខាក្រុមហ៊ុនធានារ៉ាប់រងបរទេស ដែលកំពុងធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចផ្ដល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេល នូវពតិមានសំខាន់ៗដែលពាក់ព័ន្ធដល់ការប្រែប្រួលដើមទុនសមាសភាពអ្នកចូលហ៊ុននិងធនក្ស័យនៃក្រុមហ៊ុនមេរបស់ខ្លួននៅបរទេស ។

ក្នុងករណីដែលមានការដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងមេនៅបរទេសដោយអាជ្ញាធរមានសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការដកហូតអាជ្ញាប័ណ្ណដែលបានចេញឱ្យសាខារបស់ក្រុមហ៊ុនមេនោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ភ្លាមដែរ ដើម្បីដាក់ឱ្យធ្វើការជំរះបញ្ជីបិទសាខានោះទៅតាមច្បាប់ ។

**ប្រការ ១០.-**

សេចក្ដីសំរេចដកហូតអាជ្ញាប័ណ្ណជាស្ថាពរពីក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង នឹងនាំទៅដល់ការរំលាយក្រុមហ៊ុននោះតាមផ្លូវច្បាប់ ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២.-**

ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៩៣៦ សហវ.ប្រក.

# ប្រកាស

## ស្តីពី

## ការកែសំរួលអត្រាពន្ធ និងអាករលើទំនិញមួយចំនួន (ស្រាបៀរ)

### ទេសរដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃ ទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០

- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសំរួលអាត្រាពន្ធ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសំរួលអាត្រាពន្ធ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញប្រកាសលេខ ៣៤១ ប្រក/សហវ/៣៨ ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- យោងស្មារតីនៃការប្រជុំនាថ្ងៃទី ១៩ និង ២០ វិច្ឆិកា ឆ្នាំ ២០០១ របស់គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៧

## សំរេច

**ប្រការ ១.**

ត្រូវបានកែប្រែ និងកំណត់អត្រាអាករពិសេស **២០ ភាគរយ** លើមុខទំនិញស្រាបៀរដែលមានទីតាំងរងលេខ ២២០៣.០០.១០ ២២០៣.០០.៩០ នៃតារាងពន្ធគយកម្ពុជាជាធរមាន ។

**ប្រការ ២.**

យោងតាមផ្នែកទី ២.១ និង ២.២ នៃប្រកាស លេខ ៣៤១ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ១៩៩៧ ស្តីពីអាករពិសេសលើទំនិញនិងសេវាមួយចំនួន, អ្នកនាំចូល និងផលិតករក្នុងស្រុក ត្រូវមានកាតព្វកិច្ចបង់អាករពិសេសលើស្រាបៀរ ដូចខាងក្រោម:

១-ចំពោះអ្នកនាំចូល ត្រូវបង់អាករពិសេសលើស្រាបៀរនាំចូលដោយផ្អែកលើតំលៃក្នុងគយ បូកបន្ថែមពន្ធ និងអាករដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសលើខ្លួនឯង និងអាករលើតំលៃបន្ថែមដែលបានបង់នាពេលនាំចូល, នៅមុនពេលយកទំនិញចេញពីការឃុំគ្រងរបស់ទីចាត់ការគយ និងរដ្ឋាករ ។

២- ចំពោះផលិតករក្នុងស្រុក ត្រូវប្រមូលអាករពិសេសនៅពេលធ្វើការផ្គត់ផ្គង់ស្រាបៀរទាំងនោះ ដោយផ្អែកលើថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយបត្រ។

**ប្រការ ៣.**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០២ នេះតទៅ ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

**គាត ឈន់**

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីមុខងារ"
- គ្រប់អង្គភាពពន្ធដារ-ទីចាត់ការគយ និង រដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៩ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០០១

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការបើកទូលាយទីផ្សារធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបជាដំណឹងដល់អ្នកវិនិយោគទុនក្នុងស្រុក និងបរទេសព្រមទាំងពាណិជ្ជករទាំងអស់ដែលមានបំណងប្រកបអាជីវកម្មលើវិស័យធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជាបានជ្រាបថា ចាប់ពីពេលនេះតទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណធានារ៉ាប់រង សំរាប់បង្កើតក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងហើយ ។

ពត៌មានពិស្ដារផ្សេងទៀត អាចទំនាក់ទំនងជាមួយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ "ការិយាល័យធានារ៉ាប់រង" ដែលស្ថិតនៅជាន់ទី ២ អាគារ **ភាមិនភូ** កាច់ជ្រុងវិថីព្រះមហាក្សត្រីយានីកុសមៈ (១០៦) និង វិថីព្រះអង្គអេង (១៣) សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ។

ទូរស័ព្ទលេខ: ៤២៧ ៩១០ / ៤២៧ ៩៣៥ / ០១២ ៨៥២ ៩៩៧ / ០១២ ៨២៣ ៩៤២ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ១៤៥ [illegible] ២០០១

ភ្នំពេញ,ថ្ងៃទី ២០ ខែ ៤ ឆ្នាំ ២០០១

## ប្រកាស
## រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងយុត្តិធម៌
- បានឃើញច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលបានប្រកាសអោយប្រើដោយក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច

ប្រការ១ : ផ្ទេរក្របខ័ណ្ឌ និងឥណទានបៀវត្ស របស់ក្រឡាបញ្ជី បំរើការនៅតុលាការក្រុងភ្នំពេញ ចំនួន ៣០ រូប អោយមកបំរើការងារ នៅក្រសួងយុត្តិធម៌ ៖

| ល.រ | គោត្តនាម និង នាម | ភេទ | អង្គភាពដែលត្រូវទៅបំរើការងារ |
|---|---|---|---|
| ១ | រស់ អូន | ប្រុស | ក្រសួងយុត្តិធម៌ |
| ២ | លី វ៉េងហេង | ប្រុស | ក្រសួងយុត្តិធម៌ |
| ៣ | ថេង រ៉ាមី | ប្រុស | ក្រសួងយុត្តិធម៌ |
| ៤ | ហ៊ី រត្ន័ | ប្រុស | ក្រសួងយុត្តិធម៌ |
| ៥ | សុង ប៊ុណ្ណារិទ្ធិ | ប្រុស | ក្រសួងយុត្តិធម៌ |
| ៦ | ជៀប ឡុង | ប្រុស | ក្រសួងយុត្តិធម៌ |
| ៧ | ស៊ូ លក្ខិណា | ស្រី | ក្រសួងយុត្តិធម៌ |
| ៨ | ឈុំ វណ្ណដា | ស្រី | ក្រសួងយុត្តិធម៌ |
| ៩ | សូ ចាន់ធី | ប្រុស | ក្រសួងយុត្តិធម៌ |
| ១០ | អោក មានិត | ប្រុស | ក្រសួងយុត្តិធម៌ |
| ១១ | ផាន់ ពិសិដ្ឋ | ប្រុស | ក្រសួងយុត្តិធម៌ |
| ១២ | កែវ សុម៉ុង | ស្រី | ក្រសួងយុត្តិធម៌ |

| | | | |
|---|---|---|---|
| ១៣ | វ៉ាយ សុផល | ស្រី | ក្រសួងយុត្តិធម៌ |
| ១៤ | សេង សុខហេង | ប្រុស | ក្រសួងយុត្តិធម៌ |
| ១៥ | សាយ ប្រសិទ្ធ | ប្រុស | ក្រសួងយុត្តិធម៌ |
| ១៦ | ជា សុខហៀង | ប្រុស | ក្រសួងយុត្តិធម៌ |
| ១៧ | តូច ប៊ុន្នី | ស្រី | ក្រសួងយុត្តិធម៌ |
| ១៨ | បាន សោភ័ណ | ស្រី | ក្រសួងយុត្តិធម៌ |
| ១៩ | វង្ស ច័ន្ទបុប្ផ | ស្រី | ក្រសួងយុត្តិធម៌ |
| ២០ | អ៊ុក សារឿន | ប្រុស | ក្រសួងយុត្តិធម៌ |
| ២១ | យន់ ណារ៉ុង | ប្រុស | ក្រសួងយុត្តិធម៌ |
| ២២ | អ៊ុំ វិសាខា | ស្រី | ក្រសួងយុត្តិធម៌ |
| ២៣ | អឿង បុប្ផា | ប្រុស | ក្រសួងយុត្តិធម៌ |
| ២៤ | សួស ឡា | ប្រុស | ក្រសួងយុត្តិធម៌ |
| ២៥ | សៀង គ្រុយ | ប្រុស | ក្រសួងយុត្តិធម៌ |
| ២៦ | ឈុន លក្ខិណា | ស្រី | ក្រសួងយុត្តិធម៌ |
| ២៧ | គង់ សំសារ៉េត | ប្រុស | ក្រសួងយុត្តិធម៌ |
| ២៨ | ព្រឹម មករន្ទ | ប្រុស | ក្រសួងយុត្តិធម៌ |
| ២៩ | ហ៊ឹម សេរីវុឌ្ឍ | ប្រុស | ក្រសួងយុត្តិធម៌ |
| ៣០ | សេង ប៊ុនថេន | ប្រុស | ក្រសួងយុត្តិធម៌ |

ប្រការ ២- ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់អង្គភាពដើម ។

ប្រការ ៣- ខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ " ការិយាល័យគណនេយ្យ" នៃក្រសួងយុត្តិធម៌ តុលាការក្រុងភ្នំពេញ និងសាម៉ីខ្លួន មានភារកិច្ចអនុវត្តនូវសេចក្តីប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

នេត.សាវឿន

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ដូចប្រការ ៣
( ដើម្បីជូនជ្រាប និងអនុវត្ត )
-កាលប្បវត្តិ-ឯកសារ ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៚៚

ក្រសួងធម្មការ និង សាសនា

លេខ ៣១៤.......ក.ធ.ស ការ

## សេចក្តីសម្រេច

### ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនៃក្រុមប្រឹក្សាសម្ព័ន្ធគ្រិស្ទានដំណឹងល្អខ្មែរ នៅខេត្តពោធិសាត់ របស់លោក **សឿន ថាន** ភេទប្រុស អាយុ ៣៧ ឆ្នាំ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៦
- យោងចំណារបញ្ជូនរបស់សាលាខេត្តពោធិសាត់លេខៈ ១១៩១៩ពស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០

## សម្រេច

<u>ប្រការ១</u>: អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **រដ្ឋចម្រើន** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិចំការចេក ឃុំផ្ទះព្រៃ ស្រុកបំពៅមាស ខេត្តពោធិសាត់ ។

<u>ប្រការ២</u>: សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **រដ្ឋចម្រើន** " ត្រូវអនុញ្ញាតឱ្យ ប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី ខែ ឆ្នាំ

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **រដ្ឋខចំរូន** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ ក្រសួងធម្មការ និង សាសនា។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៏ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ - នាយកដ្ឋានរដ្ឋបាល - អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន - អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធ ត្រូវសហការណ៏អនុវត្តន៏សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០១

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

" ដើម្បីគោរពជូនជ្រាប "

- រាជកិច្ច ( ដើម្បីចុះផ្សាយ )
- សាលាខេត្តពោធិសាត់
- មន្ទីរធម្មការ និងសាសនា ខេត្តពោធិសាត់
- សាខាស្នាក់ការ " **រដ្ឋខចំរូន** "

" ដើម្បីមុខការ "

- ឯកសារ,កាលប្បវត្តិ

**ជា_សាវឿន**